**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងការបរទេស**
**និងសហប្រតិបត្តិការអន្តរជាតិ**
នាយកដ្ឋានព័ត៌មាន

# សេចក្តីជូនព័ត៌មាន

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃរដ្ឋាភិបាលព្រះរាជាណាចក្រកម្ពុជា នឹងដឹកនាំគណៈប្រតិភូជាន់ខ្ពស់ អញ្ជើញទៅចូលរួម«កិច្ចសន្ទនាក្រៅផ្លូវការរវាងថ្នាក់ដឹកនាំនៃកិច្ចសហប្រតិបត្តិការសេដ្ឋកិច្ចអាស៊ី-ប៉ាស៊ីហ្វិក (APEC) និងអាស៊ាន» ដែលនឹងប្រព្រឹត្តទៅនៅថ្ងៃទី ១០ ខែវិច្ឆិកា ឆ្នាំ២០១៧ នៅទីក្រុងដាណាំង តបតាមការអញ្ជើញ របស់ **ឯកឧត្តម ត្រាន ដាយ ក្វាង** ប្រធានរដ្ឋនៃសាធារណរដ្ឋសង្គមនិយមវៀតណាម ។

គណៈប្រតិភូអមដំណើរ រួមមាន **ឯកឧត្តម ប៉ាន សូរស័ក្តិ** រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម **ឯកឧត្តមបណ្ឌិត ហង់ ជួនណារ៉ុន** រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា ព្រមទាំងសមាជិករដ្ឋាភិបាលព្រះរាជាណាចក្រកម្ពុជាដទៃទៀត។

ក្រោមមូលបទ «ការចូលរួមជាដៃគូដើម្បីថាមភាពថ្មីសម្រាប់សមាហរណកម្ម និងការតភ្ជាប់គ្រប់ជ្រុងជ្រោយនៃតំបន់អាស៊ី-ប៉ាស៊ីហ្វិក» កិច្ចសន្ទនាក្រៅផ្លូវការនេះ នឹងផ្តល់ឱកាសដ៏ល្អដើម្បីស្វែងរកវិធីសម្រាប់កិច្ចសហប្រតិបត្តិការថ្មី រវាងយន្តការតំបន់ទាំងពីរនេះ ក្នុងការលើកកម្ពស់សន្តិភាព និងវិបុលភាព ។

ប្រទេសកម្ពុជា ក្នុងនាមជាប្រទេសមិនមែនជាសមាជិកនៃកិច្ចសហប្រតិបត្តិការសេដ្ឋកិច្ចអាស៊ី-ប៉ាស៊ីហ្វិក បានគាំទ្រគំនិតផ្តួចផ្តើមក្នុងការបង្កើតវេទិកាសម្រាប់កិច្ចពិភាក្សារវាងថ្នាក់ដឹកនាំអាស៊ាន និងកិច្ចសហប្រតិបត្តិការសេដ្ឋកិច្ចអាស៊ី-ប៉ាស៊ីហ្វិក ជាមួយការយល់ឃើញថាស្ថាបត្យកម្មតំបន់ដ៏សំខាន់ទាំងពីរ គួរតែបំពេញបន្ថែមគ្នាទៅវិញទៅមក ក្នុងការកំណត់អនាគតរបស់តំបន់។

ក្នុងអំឡុងពេលស្នាក់នៅប្រទេសវៀតណាម **សម្តេចតេជោ** នឹងអញ្ជើញចូលជួបសម្តែងការគួរសមជាមួយ**ឯកឧត្តម ត្រាន ដាយ ក្វាង** ប្រធានរដ្ឋនៃសាធារណរដ្ឋសង្គមនិយមវៀតណាម និងអញ្ជើញចូលរួមពិសារអាហារពេលព្រឹកការងារ រៀបចំដោយឯកឧត្តម **ង្វៀន សួនហ៊្វុក** ( Nguyen Xuan Phuc ) នាយករដ្ឋមន្ត្រីនៃសាធារណរដ្ឋសង្គមនិយមវៀតណាម ។

គួរបញ្ជាក់ផងដែរថា សម្តេចតេជោនាយករដ្ឋមន្ត្រី បានអញ្ជើញចូលរួម«កិច្ចសន្ទនានៃកិច្ចសហប្រតិបត្តិការសេដ្ឋកិច្ចអាស៊ី-ប៉ាស៊ីហ្វិកដើម្បីពង្រឹងភាពជាដៃគូនៃការតភ្ជាប់» និង«កិច្ចប្រជុំកំពូលនាយកប្រតិបត្តិនៃកិច្ចសហប្រតិបត្តិការសេដ្ឋកិច្ចអាស៊ី-ប៉ាស៊ីហ្វិក» ដែលបានប្រព្រឹត្តទៅកាលពីថ្ងៃទី០៧ ដល់ថ្ងៃទី០៩ ខែវិច្ឆិកា ឆ្នាំ២០១៤ នៅទីក្រុងប៉េកាំង សាធារណរដ្ឋប្រជាមានិតចិន។

រាជធានីភ្នំពេញ ថ្ងៃទី 08 ខែវិច្ឆិកា ឆ្នាំ២០១៧


អាសយដ្ឋានៈ លេខ ៣ វិថី សម្តេច ហ៊ុន សែន
សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន
រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា

ទូរស័ព្ទ : (855) 23 214 441, 216 122
ទូរសារ : (855) 23 216 144, 216 141
អ៊ីម៉ែល : mfaic@mfa.gov.kh